**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតអបអរសាទរ

## សូមផ្ញើជូន

## ឯកឧត្តម ហ៊ី សោភា ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ឯកឧត្តម ជាទីគោរពរាប់អាន !

នៅក្នុងឱកាសដ៏មហាឧត្តុង្គឧត្តមប្រសើរថ្លៃថ្លា ប្រកបដោយក្តីសោមនស្សរីករាយ ខ្ញុំនិងភរិយាសូមចូលរួមអបអរសាទរចំពោះឯកឧត្តម ក្នុងឱកាស**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ត្រាស់បង្គាប់តែងតាំងមុខតំណែងជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងអាណត្តិ៣ឆ្នាំ លើកទី១០ "ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៨"។

ការត្រាស់បង្គាប់តែងតាំងមុខតំណែងជា ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ពិតជាស័ក្តិសមបំផុតចំពោះស្នាដៃ គុណវុឌ្ឍិ ផ្នែកចំណេះដឹង បទពិសោធន៍ និងទេពកោសល្យរបស់ឯកឧត្តម ដែលបានបំពេញបេសកកម្មដ៏ថ្លៃថ្លា បម្រើការពារផលប្រយោជន៍ **ជាតិ សាសនា ព្រះមហាក្សត្រ** ពិសេសបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការលើកកម្ពស់វិស័យយុត្តិធម៌ ពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ភាពសុខសាន្តរបស់ប្រជាជន ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ជាថ្មីម្តងទៀត ខ្ញុំនិងភរិយាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយបីបាច់ថែរក្សាប្រទានពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរគ្រប់ប្រការជូនចំពោះ ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម ហ៊ី សោភា ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំនិងភរិយា។

ថ្ងៃសុក្រ ២កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**